# ការយល់ដឹងអំពីភេរវកម្ម

## តើអ្វីទៅភេរវកម្ម?

ភេរវកម្មគឺជាការប្រើ កម្លាំងគំរាមកំហែងឬធ្វើអំពើយ៉ាង សាហាវឃោរឃៅ ប្រឆាំងទល់នឹង មនុស្សជាតិ ឬធនធានទ្រព្យសម្បត្តិ ដែលល្មើសនឹងច្បាប់ឧក្រិដ្ឋ នៃសហរដ្ឋអាមេរិក (ឬប្រទេសនានា) ដោយគោលបំណង បំភិតបំភ័យ, បង្ខិតបង្ខំ, ឬ [ ចំរិត (ជាប្រាក់, ទ្រព្យសម្បត្តិ ឬជីវិតមនុស្ស?) ] ។ ពួកភេរវករ ជាញឹកញាប់ណាស់ គេប្រើ ការគំរាមកំហែង ដើម្បីបង្កើតឱ្យមាន ការភិតភ័យ ជាសាធារណៈ, ដើម្បីព្យាយាមធ្វើឱ្យប្រជាពលរដ្ឋជឿថា រដ្ឋាភិបាលរបស់គេខ្សោយ គ្មានអំណាច ក្នុងការពារពីអំពើភេរវកម្ម, ហើយពួកគេចង់បាន ការផ្សព្វផ្សាយ ឱ្យបានឆាប់រហ័ស ចំពោះការបង្ករ ហេតុរបស់គេនោះ ។

## របៀបនៃភេរវកម្ម

គ្រប់អំពើឬចលនានៃភេរវកម្មទាំងអស់ គឺជាឧក្រិដ្ឋកម្ម ។ ការិយាល័យស៊ើបអង្កេតរបស់សហព័ន្ធ (FBI) បានចាត់អំពើភេរវកម្ម នៅក្នុងសហរដ្ឋអាមេរិក ជាពីរយ៉ាង - ភេរវកម្មក្នុងស្រុក និង ភេរវកម្មអន្តរជាតិ ។

**ភេរវកម្មក្នុងស្រុក** មានពាក់ព័ន្ធជាក្រុមៗ ជាបុគ្គលនិមួយៗ គឺភេរវករ ដែលធ្វើសកម្មភាពផ្ទាល់ នៅក្នុងជួររដ្ឋាភិបាល ឬជួរប្រជាពលរដ្ឋ ដោយមិនមាន ការណែនាំ មកពីខាងក្រៅប្រទេស ។

**ភេរវកម្មអន្តរជាតិ** មានពាក់ព័ន្ធជាក្រុមៗ ជាបុគ្គលនិមួយៗ គឺភេរវករ ដែលធ្វើសកម្មភាព ដែលមានមូលដ្ឋាន ចេញមកពីបរទេស ហើយនិង/ឬក៏បានបញ្ជារចេញមកពី ប្រទេសនានា ឬក្រុមនានា នៅខាងក្រៅសហរដ្ឋអាមេរិក ឬសកម្មភាព ចេញពីអ្នកតស៊ូនៅខាងក្នុងរង្វង់ព្រំដែនសីមា ។

## ធម្មជាតិនិងលក្ខណៈនានានៃភេរវកម្ម

ពួកភេរវករ គេរកមើលកន្លែងណាដែលមាន ចំណុចសំខាន់ៗ ដែលអាចមើលឃើញលិចធ្លោជាងគេ ហើយដែលពួកគេអាច គិចខ្លួនបានស្រួល កុំឱ្យគេដឹង មុននឹងវាយប្រហារ ឬក្រោយពីការវាយប្រហារ ដូចជានៅតាម ព្រលានយន្តហោះអន្តរជាតិនានា, ក្រុងធំៗ, កន្លែងដែលគេធ្វើបុណ្យទាន ឬទីកន្លែងប្រជុំជនធំៗ ជាអន្តរជាតិនានា, ទីកន្លែងកំសាន្តនានា, ហើយនិងទីកន្លែងនានា ដែលល្បីល្បាញជាងគេ ក្នុងប្រវត្តិសាស្ត្រ (បើនៅស្រុកខ្មែរយើង ដូចជាតំបន់ប្រាសាទអង្គរជាដើម?) ។ សកម្មភាពនានារបស់ភេរវករ គឺគេបានដាក់ជាគំរោងការណ៍ ច្បាស់លាស់ហើយហ្មត់ចត់ណាស់ ហើយជាធម្មតា គឺគេត្រូវតែធ្វើ ដោយមិនងាយងាករេចេញពី គំរោងការណ៍របស់គេទេ ។ គឺវាធ្វើហ្នឹង ដើម្បីជាការកំហែង, ជាការបង្កើតឱ្យមាន ប្រតិកម្មជាក់ស្តែង ចេញមកពីសវនក (ប្រជាជន) ។ ជាធម្មតាភេរវករ គេនឹងសំដែងសាកល្បងមើល ហើយគេសមហាត់គ្នា នូវគំរោងការណ៍របស់គេ យ៉ាងហោចណាស់ក៏បីដងដែរ មុននឹងធ្វើការវាយប្រហារ មែនទែននោះ ។ ទិសដៅភេរវកម្ម គឺគេត្រូវបានណែនាំ (ឬបញ្ជារ) ឱ្យធ្វើការប្រឆាំងទល់នឹង រដ្ឋាភិបាលនានា, ហាងជំនួញនានា, សហគមន៍នានា, ហើយនិងបុគ្គលនិមួយៗ ។ គឺគេធ្វើដើម្បី ជាការសងសឹក ដែលគេយល់ថាវាមិនមានយុត្តិធម៌ សំរាប់ពួកគេ ធ្វើដើម្បីឱ្យវាមានការ ប្រឈមមុខដាក់គ្នា រវាងបក្សពួកនានា; ធ្វើឱ្យរិតតែប្រសើរឡើង នូវការទាមទារចង់បានរបស់គេ; ឬក៏គេចង់បង្ហាញឱ្យឃើញថា គេមានកម្លាំងខ្លាំងក្លា ឬគេហ្នឹងខ្លាំង, គេមានការស៊ូប្តូរផ្តាច់ចំពោះ, ហើយគេមឹងម៉ាត់ហ្មត់ចត់ ។

មុននឹងពួកភេរវករ បានវាយប្រហារកន្លែងណាមួយ, ពួកធ្វើសកម្មភាពទាំងនោះ ត្រូវបានពួករក្សាសន្តិសុខ គេឃ្លាំមើល និងត្រូវបានថតទុក ដោយម៉ាស៊ីនវីឌីអូខែមរ៉ាស្វ័យប្រវត្តិ ។ យ៉ាងណាក៏ដោយ, នៅពេលដែលភេរវករ មិនទាន់បានចូលដល់ ទៅខាងក្នុង ទីកន្លែងឬអាគារ (ដែលនឹងត្រូវធ្វើការវាយប្រហារ), ក្នុងករណីនិមួយៗនេះ ពួកអ្នករក្សាសន្តិសុខ ត្រូវមានការប្រុងប្រយ័ត្នកំរិតខ្ពស់ និងត្រូវធ្វើហាក់ដូចជា ព្រងើយកន្តើយសិន ។ ពួកភេរវករខ្លះ គេបានទៅត្រួតពិនិត្យមើល ឬសើបអង្កេតមើល មានថតរូប ហើយគូសព្រាងនូវទីកន្លែង (ដែលគេត្រូវវាយប្រហារ), ករណីនេះ បុគ្គលិកអ្នករក្សាសន្តិសុខ មិនទាន់គិតថាវាសំខាន់ ទៅបញ្ឈប់ ឬទៅសួរគេទេ ។ គ្រឿងឧបករណ៍របស់ភេរវករ ដូចជារថយន្តនានា ដែលមានគ្រឿងផ្ទុះ បានកំពុងចតនៅកន្លែង ដែលគេ "ហាមមិនឱ្យចត" មិនទាន់បានសើបអង្កេត ឬកំណត់ថា ជាឡាន

នរណានៅឡើយទេ ។ ចូរចងចាំថា, ជាធម្មតាភេរវករ នឹងមិនវាយប្រហារទេ យ៉ាងហោចណាស់ គេត្រូវជឿថា ការអនុវត្តន៍របស់គេនោះ វានឹងបានសម្រេចជោគជ័យ មួយរយភាគរយ (១០០%) ទើបគេវាយប្រហារ ។

ពួកភេរវករ គេចង់បានក្រសួងពត៌មានដឹងឮផ្សព្វផ្សាយ ដើម្បីធានាឱ្យប្រជាជនភាគច្រើន បានដឹងបានឮអំពីសកម្មភាពរបស់គេ ។ ពួកភេរវករខ្លះ នឹងអាចប្រើទូរស័ព្ទហៅប្រាប់ ទៅក្រសួងពត៌មានមុននឹងគេធ្វើសកម្មភាព ឬក៏ហៅប្រាប់ នៅកន្លែងកើតហេតុតែម្តង បន្ទាប់ពីពួកគេបានធ្វើសកម្មភាពហើយ ។ អញ្ចឹងហើយទើបានគេ ជ្រើសរើសរកកន្លែងណា ដែលសំខាន់ៗ ក្នុងគោលបំណង ដើម្បីធ្វើឱ្យមានការ ខូចខាតជាដំណំនោះ ។ គឺគេចង់ឱ្យឃើញមាន "ចំនួនមនុស្សយ៉ាងច្រើនគ្រោះថ្នាក់" ។ ពួកភេរវករគេសង្ឃឹមថា ការប្រុងប្រយ័ត្នរិតតែច្រើន វាអាចញ៉ាំងឱ្យមានសេចក្តីភ័យខ្លាចរឹតែច្រើន ជាសាធារណៈ ។ ដែលអាចបណ្តាលធ្វើឱ្យរដ្ឋាភិបាលមានប្រិត្តិកម្ម, ឬអាចធ្វើឱ្យមានសេចក្តី អាណិតអាសូរច្រើន ចំពោះបុព្វហេតុរបស់គេនោះ។

ក្នុងខណៈដែលអ្នក (អ្នករក្សាសន្តិសុខ) មិនអាចការពារបាននូវបុគ្គល ដែលធ្វើឱ្យមាភាពចលាចល និងគ្រោងការវាយប្រហារ ទល់នឹងគោលដៅ ដែលគេត្រូវបំផ្លាញនោះ, អ្នកការពារសន្តិសុខ អាចកាត់បន្ថយបាន នូវការប្រឹងប្រែងព្យាយាមរបស់ពួកគេ គឺឱ្យវានៅតិចតួចជាទីបំផុត ដោយត្រូវមានការរៀបចំ ផែនការយ៉ាងហ្មត់ចត់ និងឬក៏គ្រាន់តែធ្វើការងារ ដែលគេបានបង់ថ្លៃឱ្យធ្វើបានហើយ។ ទោះជាការគំរាមគំហែង ឬការវាយប្រហារពិតប្រាកដណាមួយ ដែលបានកើតមានឡើង វាជាភាកិច្ចរបស់ អ្នករក្សាការពារសន្តិសុខ នៅជួរមុខ ។ ជាធម្មតាពួកគេ ជាអ្នកត្រូវមកដល់មុនគេ នៅកន្លែងកើតហេតុ; ដើម្បីក្តោបក្តាប់ (សង្កេតមើល) ស្ថានការណ៍; ជាអ្នកមុនគេ ចាំបាច់ត្រូវតែហៅ (ធ្វើសេចក្តីរាយការណ៍) ទៅក្រសួងអ្នកទទួលខុសត្រូវខ្ពស់ខាងផ្នែកជួយសង្គ្រោះបន្ទាន់; ជាអ្នកដំបូងគេ ដែលត្រូវទទួលខុសត្រូវ នូវស្ថានការណ៍; ជាអ្នកដំបូងគេ ត្រូវចាត់ចែងជួយសង្គ្រោះ ជនរងគ្រោះ រហូតទាល់តែ ភ្នាក់ងារ អ្នកជួយសង្គ្រោះបន្ទាន់មកដល់; ហើយជាអ្នកផ្តល់ពត៌មាន យ៉ាងល្អិតល្អន់ ច្បាស់លាស់ មុនគេ នូវហេតុការណ៍ទាំងឡាយ ដែលបានកើតមានឡើង ទៅភ្នាក់ងារអ្នកទទួលខុសត្រូវនានា ។

## របៀបវិធីការពារជាក់ស្តែងឆ្លើយតបចំពោះភេរវករ

- ការធ្វើឱ្យញញើត - ការធ្វើឱ្យរុញរាឬស្ទាក់ស្ទើរ នូវសកម្មភាពរបស់ភេរវករ គឺធ្វើឱ្យមានការពិបាក ក្នុងការវាយប្រហារ, ដូច្នេះភេរវករ មិនអាចមានលទ្ធភាព ធ្វើបានជោគជ័យមួយរយភាគរយ (១០០%)ទេ។ រីឯវិធីទាំងអស់នោះមានដូចតទៅៈ ការពិនិត្យឬឆែកឆេរនូវអត្តសញ្ញាណប័ណ្ណនានា, កញ្ចប់ឬប្រអប់នានា, ហើយនិងរថយន្តនានា មុននឹងពួកគេអាចចូលបាន ទៅក្នុងកន្លែងសន្តិសុខ, ធ្វើការយាមល្បាត ទៅតាមផ្លូវនានា ដោយធ្វើដំណើរមិនឱ្យគេដឹងជាមុន, ហើយថែរក្សានូវ ការសម្ងាត់នានា គ្រប់ពេលវេលា ។

- ការពន្យា - គឺធ្វើឱ្យមានការបង្អែរបង្អង់ ដោយការប្រើប្រាសនូវ រនាំងរាំងរានានា, បិទទ្វារចាក់សោរ, ហៅកងកម្លាំងជំនួយ, ហើយនិងពិនិត្យមើលគ្រប់គ្រង គ្រប់យានយន្តដែលចេញចូល ។

- ការបដិសេធ - គឺមិនព្រមឱ្យពួក ភេរវករនានា ប្រើប្រាសពង្រីកឬបង្កើននូវ ភាពចលាចលឬភាពភ័យស្លន់ស្លោ ហើយនិងមិនអាចអនុញ្ញាត ឱ្យពួកគេ អាចទាក់ទងបាននូវប្រព័ន្ធផ្សព្វផ្សាយដំណឹង, ដែលពួកគេព្យាយាមចង់បាន ដើម្បីជាផលប្រយោជន៍របស់គេ ។

- ការដឹងបាន - ការចាប់ដំណឹងបាន ឬការដឹងហេតុការណ៍ នៃសកម្មភាពរបស់ភេរវករដែលអាចសម្រេចទៅបាន ដោយការវិភាគ របស់ភ្នាក់ងារអ្នកយកការណ៍ពិសេស ។ វាអាចបង្ហាញឱ្យយើងដឹងបានផងដែរ តាមរយៈការឆែកឆេរ, ការប្រើប្រាសម៉ាស៊ីនរាវរកជាតិផ្ទុះ (រស្មីអ៊ិក្ស, ប្រដាប់ពិនិត្យគ្រឿងផ្ទុះ), ហើយនិង ប្រដាប់ម៉ាស៊ីនទូរទស្សន៍ដែលថតឆ្លុះគ្នា ដោយស្វ័យប្រវត្តិ ។